# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៦.សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារសិក្សាបឋមសម្រាប់គម្រោងប្រព័ន្ធពត៌មានវិទ្យារដ្ឋបាលខេត្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងារសិក្សាបឋម ស្តីពីគម្រោងប្រព័ន្ធពត៌មានវិទ្យារដ្ឋបាលខេត្ត ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | គូ លីឌុល្ល | អគ្គលេខាធិការ NIDA | ប្រធាន |
| ២. លោក | ឡាយ ម៉ារីទូ | អគ្គនាយករងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៣. លោក | អ៊ុយ ឆួន | ប្រធាននាយកដ្ឋានបច្ចេកទេសក្រសួងពត៌មាន | សមាជិក |
| ៤. លោក | ចាន់ សុជាទាត់ | នាយកផែនការ EDC | សមាជិក |
| ៥. លោក | អម មង្គល | អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅក្រសួងមហាផ្ទៃ | សមាជិក |
| ៦. លោក | សួន ណាយ | មន្ត្រី NIDA | សមាជិក |

**ប្រការ ២.-**

ក្រុមការងារនេះត្រូវសហការជាមួយអ្នកបច្ចេកទេសក្លូរ៉េ ដើម្បីពិនិត្យការសិក្សាបឋមឡើងវិញ និងធ្វើការកែលំអរបន្ថែមលើឯកសារសិក្សាបឋមដែលមានស្រាប់។

**ប្រការ ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិងថាមពល និងសាមីខ្លួនដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តី សម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ តុលា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចចែងក្នុងប្រការ ៣*
- *ឯកសារ-កាលប្បវត្តិ*